**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"**

# សេចក្តីជូនដំណឹងស្តីពី

# ការលុបការស្នើសុំបង្កើតគណនី CamDigiKey ដែលបានដាក់ស្នើតាមរយៈកម្មវិធីទូរស័ព្ទដៃ CamDigiKey ក្រោយការ "បញ្ជូនត្រលប់" ឱ្យកែតម្រូវព័ត៌មានលើសរយៈពេល ៣ ខែ

មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" (ម.ធ.ត.) មានកិត្តិយស សូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់ មេត្តាជ្រាបថា៖ គិតត្រឹមថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០២៣ នេះ, ម.ធ.ត. បានអនុម័តការស្នើសុំបង្កើតគណនី CamDigiKey របស់អ្នកប្រើប្រាស់ (Individual User) ដែលបានដាក់ស្នើតាមរយៈកម្មវិធីទូរស័ព្ទដៃ CamDigiKey ចំនួន ២២ ៦៥៦ គណនី ដោយការស្នើសុំនីមួយៗត្រូវបានអនុម័ត(ដោគជ័យ) ក្នុងរយៈពេលយ៉ាងយូរ ៨ ម៉ោងនៃម៉ោងធ្វើការ ក្នុងករណីអ្នកស្នើសុំបានផ្តល់ព័ត៌មានត្រឹមត្រូវ ដែលបញ្ជាក់អត្តសញ្ញាណពិតប្រាកដដូចមាននៅក្នុងទិន្នន័យបច្ចុប្បន្ន-ភាពចុងក្រោយ (Latest Update) នៃទិន្នន័យអត្តសញ្ញាណកម្មរបស់ក្រសួងមហាផ្ទៃ។

ក្នុងករណីក្រុមការងារ ម.ធ.ត. ពិនិត្យឃើញថា មានព័ត៌មានណាមួយដែលផ្តល់ដោយអ្នកស្នើសុំ មិនត្រឹមត្រូវក្រោយពីបានផ្ទៀងផ្ទាត់ជាមួយទិន្នន័យអត្តសញ្ញាណកម្ម ដែលបានធ្វើបច្ចុប្បន្នភាពចុងក្រោយដោយក្រសួងមហាផ្ទៃ, ក្រុមការងារ ម.ធ.ត. នឹង **"បញ្ជូនត្រលប់ (Return)"** ពាក្យស្នើសុំនោះតាមរយៈការជូនដំណឹង នៅក្នុងកម្មវិធីទូរស័ព្ទដៃ CamDigiKey របស់អ្នកស្នើសុំ ដើម្បីផ្តល់លទ្ធភាពក្នុងការកែតម្រូវព័ត៌មានណាមួយដែលមិនត្រឹមត្រូវ រួចដាក់ស្នើម្តងទៀត។ គិតត្រឹមថ្ងៃទី១៥ ខែ ឧសភា ឆ្នាំ ២០២៣ នេះ, ករណីនៃការស្នើសុំដែលត្រូវបញ្ជូនត្រលប់មានចំនួនដល់ទៅ ៣ ០១២ ករណី។

ក្នុងន័យនេះ ***រាល់ការស្នើសុំបង្កើតគណនី CamDigiKey ទាំងអស់ ដែលមិនបានកែតម្រូវព័ត៌មាន ជាការឆ្លើយតបទៅនឹងការ "បញ្ជូនត្រលប់" របស់ក្រុមការងារ ម.ធ.ត. លើសរយៈពេល ៣ ខែ រាប់ចាប់ពីពេលដែលបានបញ្ជូនត្រលប់***, ការស្នើសុំបង្កើតគណនីនោះនឹងត្រូវបាន***លុបចេញពីប្រព័ន្ធដោយស្វ័យប្រវត្តិ*** ។ ក្នុងករណីអ្នកស្នើសុំមានបំណងស្នើសុំបង្កើតគណនីម្តងទៀត ក្រោយការលុបចេញពីប្រព័ន្ធ, អ្នកស្នើសុំអាចដាក់ស្នើសាជាថ្មី តាមរយៈកម្ម-វិធីទូរស័ព្ទដៃ CamDigiKey ។ ថ្នាល CamDigiKey គឺជាប្រព័ន្ធសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថល (Electronic Know-Your-Customer ឬ e-KYC) ដែលតម្រូវឱ្យអ្នកប្រើប្រាស់ទាំងអស់បញ្ជាក់ពីអត្តសញ្ញាណពិតប្រាកដរបស់ខ្លួនមុនពេលអាចចូលទៅប្រើប្រាស់សេវាណាមួយដែលធ្វើសន្ធានកម្មជាមួយថ្នាល CamDigiKey។ ក្នុងន័យនេះ ប្រសិនបើលោកអ្នកបានស្នើសុំបង្កើតគណនី CamDigiKey ហើយ តែមិនបានកែតម្រូវព័ត៌មាន ផ្អែកតាមមតិ "បញ្ជូនត្រលប់" នោះមានន័យថា លោកអ្នកបានបោះបង់ការស្នើសុំបង្កើតគណនី CamDigiKey របស់លោកអ្នក។

អាស្រ័យហេតុនេះ សូមសាធារណជនដែលស្ថិតក្នុងលក្ខខណ្ឌដូចបានជម្រាបជូនខាងលើ ចុចប៊ូតុង **"ពិនិត្យស្ថានភាពសំណើ"** ដើម្បីទទួលបានស្ថានភាពចុងក្រោយនៃការស្នើសុំបង្កើតគណនីរបស់លោកអ្នក ។ សម្រាប់ការស្រាយចម្ងល់ និងដោះស្រាយបញ្ហាផ្សេងៗ សូមទាក់ទងក្រុមការងារគាំទ្រ តាមរយៈទូរស័ព្ទទាន់ហេតុការណ៍ 081 888 296, គេហទំព័រហ្វេសប៊ុក (Online Business Registration Service), អ៊ីម៉ែល (registrationservices@mef.gov.kh) ឬការឆាតផ្ទាល់ (Live Chat) ដែលមានលើគេហទំព័រ www.registrationservices.gov.kh ។

*ថ្ងៃអង្គារ ១២ រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧*

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣*